# ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល　　　　　　　　　ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៤១៧　　　　　　　　　**នាមនាមប្រជាពលរដ្ឋខ្មែរ**

ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០៣　　　　**តុលាការកំពូល**

សាលដីកា

លេខ : ១៥៧

ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០០៤

បានបើកសវនាការជំនុំជម្រះ ជាសាធារណៈ នៅថ្ងៃទី ០៥ខែកញ្ញា ឆ្នាំ២០០៤ ដោយមានសមាសភាព ដូចតទៅ :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | ឌិត | មុន្ទី | ជាប្រធាន |
| ២- លោក | ស៊ិន | ឌីម | ជាចៅក្រម |
| ៣- លោក | ប្រាក់ | គីមសាន | ជាចៅក្រម |
| ៤- លោក | ប៉ែន | សាវឿន | ជាចៅក្រម |
| ៥- លោក | យូរ | ឧត្តរា | ជាចៅក្រមរបាយការណ៍ |

ក្រឡាបញ្ជី

កញ្ញា　　ធន់　　វណ្ណធឿន

តំណាងមហាអយ្យការ

លោក　　ឈួន　　ចាន់ថា　　　ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះ លើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ១៣២ " ឈ " ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៤០៦ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ រវាង :

- ដើមចោទឈ្មោះ សំ វុទ្ធី ចុងបណ្តឹងសាទុក្ខ ភេទប្រុស អាយុ ៣៦ឆ្នាំ ជាតិខ្មែរ មុខរបរ នគរបាលសេដ្ឋកិច្ច នៃ ក្រសួងមហាផ្ទៃ ទីលំនៅផ្ទះលេខ ៥ ជ ផ្លូវលេខ ២៧៣ ក្រុមទី១ ភូមិទួលគោក សង្កាត់

ទួលសង្កែ ខ័ណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ សំ ធុន " រ " ម្តាយឈ្មោះ ប៊ុន ង៉ា " រ " ប្រពន្ធឈ្មោះ លឹម ផលណារី ។

- ដើមចោទឈ្មោះ អោម ភីលន់ ភេទស្រី អាយុ ៧៦ឆ្នាំ មានទីលំនៅផ្ទះលេខ ៩ជ ផ្លូវលេខ២៧៣ ក្រុម១ ភូមិទួលគោក សង្កាត់ទួលសង្កែ ខ័ណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ម៉ី ឈុំ " ស " ម្តាយឈ្មោះ លាំង សាយ " ស " ប្តីឈ្មោះ ជា ជាម " ស " មានកូន ០១នាក់ ។

- និងចុងចម្លើយ : - ឈ្មោះ ខាន់ រ៉ែត និង ប្រពន្ធឈ្មោះ ប្រាក់ ពៅ ម្ចាស់បណ្តឹងសាទុក្ខ

- ឈ្មោះ ព្រំ នឿន " ម្តាយ "

- ឈ្មោះ ប្រាក់ ឧត្តមមុនី

មានទីលំនៅ ផ្ទះលេខ ៩ ជ ផ្លូវ ២៧៣ ក្រុម១ ភូមិទួលគោក សង្កាត់ទួលសង្កែ ខ័ណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។

- តតិយជន ឈ្មោះ ផន បញ្ញា ដើមបណ្តឹងសាទុក្ខ ភេទ ប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ មុខរបរមន្ត្រី ក្រុមប្រឹក្សាអ្នកច្បាប់ នៃ ទីស្តីការគណៈរដ្ឋមន្ត្រី ទីលំនៅផ្ទះលេខ៤0 A ផ្លូវលេខ ២២៣ សង្កាត់ផ្សារដើមគរ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។

មានមេធាវី លោក ចាន់ សុខយាង

អំពីវិវាទ : ប្តឹង សុំបែងចែកផ្ទះជាបីចំណែកស្មើគ្នា និង ឱ្យរុះរើផ្ទះ ដែលហាមឃាត់នៅខាងមុខចេញ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៤១៧ ចុះថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០០៣ របស់តុលាការកំពូល ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣៦៥ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ របស់លោក ខាន់-រ៉ែត និង ប្រពន្ធ ឈ្មោះ ប្រាក់ ពៅ មិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៣២ " ឈ " ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ លើត្រង់ចំណុច នៃ សាលដីកាទាំងមូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី ២៣-៤-២០០១ របស់ឈ្មោះ សំ វុទ្ធី និង ពាក្យបណ្តឹង ចុះថ្ងៃទី២៤-៤-២០០១ របស់ឈ្មោះ អោម ភីលន់ ប្តឹងពីឈ្មោះ ខាន់ រ៉ែត, ឈ្មោះ ប្រាក់ ពៅ, ឈ្មោះ ព្រំ នឿន និងឈ្មោះ ពេជ្យ ដោយសំអាងហេតុថា កាលពីឆ្នាំ ១៩៧៩ ខ្លួនបានចូលមករស់នៅលើផ្ទះទំនាស់នេះមុនគេ ហើយដោយមានចិត្តអាណិតដល់ឈ្មោះ ខាន់ រ៉ែត និង ឈ្មោះ ប្រាក់ ពៅ នេះ នៅឆ្នាំ១៩៨២ ក៏បានហៅឱ្យមកនៅជាមួយដែលមានឈ្មោះ ព្រំ នឿន ផងដែរ ។ ដល់ឆ្នាំ ១៩៨៤ ឈ្មោះ ព្រំ នឿន បានហៅកូនមកនៅជាមួយ ហើយបានរំលោភយកផ្ទះនេះតែម្តង ដោយបិទច្រកដើរចំកណ្តាលបណ្តាលឱ្យមានទំនាស់កើតឡើង មិនតែប៉ុណ្ណោះ ភាគីចុងចម្លើយបានរំលោភសាងសង់សំណង់នៅទីធ្លាមុខផ្ទះទំនាស់នេះទៀត ដោយរំលោភលើកិច្ចសន្យា និង អាជ្ញាធរមូលដ្ឋាន

ដែលបានបង្គាប់ឱ្យផ្អាកការសាងសង់បន្ត តែភាគីនេះ មិនស្តាប់នៅតែចចេសសាងសង់បន្តទៀត ។ ដូច្នេះក្នុងរឿងនេះ សូមតុលាការសំរេចបែងចែកផ្ទះនេះ ជាបីចំណែកស្មើគ្នា រហូតដល់ថ្នល់ និង សុំឱ្យរុះរើផ្ទះដែលហាមឃាត់ចេញពីទីធ្លាមុខផ្ទះទំនាស់ ។

បានឃើញ ដីកាសំរេចតាមពាក្យសុំ លេខ ២៦ " ក " ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០១ របស់តុលាការក្រុងភ្នំពេញ ដែលសំរេច :

១- ទទួលពាក្យបណ្តឹង ចុះថ្ងៃទី ២៣-៤-២០០១ របស់ដើមចោទឈ្មោះ សំ វុទ្ធី ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ហាមឃាត់ឈ្មោះ ខាន់ ង៉ែត ប្រពន្ធឈ្មោះ ប្រាក់ ពៅ និង ម្តាយឈ្មោះ ព្រំ នឿន មិនឱ្យធ្វើការសាងសង់ ឬ ជួសជុលសំណង់នៅលើដីទីតាំងទំនាស់មុខផ្ទះលេខ ៩ ផ្លូវ ២៧៣ សង្កាត់ទួលសង្កែ ខ័ណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ដោយរក្សាទុកឱ្យនៅសភាពដើមដដែល ជាបណ្តោះអាសន្ន រង់ចាំតុលាការសំរេចរឿងអង្គសេចក្តីចប់ជាស្ថាពរ ។

៣- បង្គាប់ឱ្យដើមបណ្តឹងបង់ប្រាក់ប្រដាប់ក្តីចំនួន ២០០០រៀល គឺពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹងចំនួន ១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល ។ ប្រាក់នេះដើមចោទបង់រួចហើយ ។

៤- បើភាគីណាមិនសុខចិត្តនឹងដីកាសំរេចខនេះ មានសិទ្ធិប្តឹងជំទាស់ក្នុងរយៈពេល ១៥ថ្ងៃ គិតពីថ្ងៃបានទទួលដំណឹងនេះតទៅ ។

បានឃើញ សាលក្រមរដ្ឋប្បវេណី លេខ ០៥ " ក " ចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០០៣ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១- កត់សំគាល់ថា ពាក្យបណ្តឹងចុះថ្ងៃទី ២៨-១០-២០០២ របស់លោក ផន បញ្ញា បានដាក់ចូលដល់តុលាការក្រោយពេល ដែលតុលាការប្រកាសបិទការសួរដេញដោល នៅពេលសវនាការ ថ្ងៃទី ២៥-១០-២០០២ តុលាការមិនលើកយកមកពិចារណាឡើយ ។

២- ទទួលពាក្យចុះថ្ងៃទី ០១-៧-២០០២ របស់មេធាវី ទូត លុច និង ពាក្យចុះថ្ងៃទី ១៣-៦-២០០១ របស់មេធាវី មៀច សំអ៊ាន់ សុំជាតំណាង និង ការពារក្តីឱ្យឈ្មោះ ព្រំ នឿន , ខាន់ ង៉ែត , ប្រាក់ ពៅ និង ប្រាក់ ឧត្តមមុនី ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣- ទទួលពាក្យតវ៉ា និង ដោះសាររបស់ចុងចម្លើយ និង មេធាវីចុងចម្លើយ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោល ដោយខាស់ និង គតិច្បាប់ ។

៤- ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ សំ វុទ្ធី និង អោម ភីលន់ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៥- បង្គាប់ឱ្យឈ្មោះ ព្រំ នឿន , ខាន់ ង៉ែត , ប្រាក់ ពៅ និង ប្រាក់ ឧត្តមមុនី ព្រមទាំងជនដទៃ ដែលពាក់ព័ន្ធ រុះរើផ្ទះចំនួន ២ខ្នង ដែលសង់ឡើងដោយព្រំ នឿន , ខាន់ ង៉ែត , ប្រាក់ ពៅ និង ប្រាក់ ឧត្តមមុនី នៅមុខផ្ទះលេខ ៩ ជ ក្រុម I ភូមិទួលគោក សង្កាត់ទួលសង្កែចេញ បើសាមីខ្លួនមិនព្រមរើ ត្រូវប្រើកម្លាំងសាធា-រណៈ ដើម្បីរុះរើចាប់ពីពេលដែលសាលក្រមនេះស្ថាពរ ។

៦- បែងចែកដីនៅមុខផ្ទះលេខ ៩ជ ក្រុម I សង្កាត់ទួលសង្កែ ខ័ណ្ឌឫស្សីកែវ ដែលរុះរើផ្ទះចេញ ឱ្យទៅបីគ្រួសារ ជាបីចំណែកស្មើៗគ្នា គឺឱ្យទៅគ្រួសារ ខាន់ ង៉ែត , ប្រាក់ ពៅ និង ប្រាក់ ឧត្តមមុនី មួយចំណែក , គ្រួសារ អោម ភីលន់ មួយចំណែក និង គ្រួសារ សំ វុទ្ធី មួយចំណែក ដើម្បីធ្វើផ្លូវពីថ្នល់ចូលផ្ទះរៀងៗខ្លួន ចាប់ពីពេលដែលសាលក្រមនេះ ស្ថាពរ លើកលែងតែមានការព្រមព្រៀងគ្នាផ្សេង ។

៧- ឱ្យចុងចម្លើយបង់ប្រដាប់ក្តី ៧.០០០រៀល ។ ប្រាក់នេះ បានកាត់យកពីប្រាក់ប្រដាប់ក្តីរបស់ដើមចោទ ដាក់ថវិការដ្ឋ និង ចំណាយផ្សេងៗ រួចហើយ ។ តម្រូវឱ្យចុងចម្លើយរួបរួមគ្នាសងប្រាក់ ៧០០០រៀល នេះទៅដើមចោទវិញ នៅពេលសាលក្រមស្ថាពរ ។

៨- សាលក្រមនេះ សំរេចសេចក្តី និង ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ សំ វុទ្ធី កំបាំងមុខយាយ អោម ភីលន់ ចំពោះមុខចុងចម្លើយ ខាន់ ង៉ែត , ប្រាក់ ពៅ , ព្រំ នឿន កំបាំងមុខ ប្រាក់ ឧត្តមមុនី តែទុកជាចំពោះមុខ និង ចំពោះមុខ លោក ផន បញ្ញា បើកផ្លូវប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

បានឃើញ បណ្តឹងឧទ្ធរណ៍ លេខ ០៣ " ក " ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៣ របស់លោក ផន បញ្ញា , លោក ខាន់ ង៉ែត , អ្នកស្រី ប្រាក់ ពៅ , អ្នកស្រី ព្រំ នឿន សុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ០៥ " ក " ចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០០៣ របស់តុលាការក្រុងភ្នំពេញលើសេចក្តីសំរេចទាំងមូល នៃ សាលក្រម ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ ១៣២ " ឃ " ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៨-០១-២០០៣ របស់ឈ្មោះ ផន បញ្ញា , ខាន់ ង៉ែត ប្រាក់ ពៅ និង ឈ្មោះ ព្រំ នឿន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- ទទួលពាក្យបណ្តឹងសុំចូលជាតតីយជន ចុះថ្ងៃទី ០៥-៨-២០០៣ របស់ឈ្មោះ ផន បញ្ញា ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៣- ចាត់បញ្ចូលឈ្មោះ ផន បញ្ញា មកជាតតីយជន ខាងភាគីចុងចម្លើយនៅក្នុងសំណុំរឿងរដ្ឋប្បវេណី លេខ ៤០៦ ចុះថ្ងៃទី ០៨-៧-២០០៣ របស់សាលាឧទ្ធរណ៍ ។

៤- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ០៥ " ក " ចុះថ្ងៃទី ២៨-០១-២០០៣ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ដោយគ្រាន់តែសំរេចបដិសេធចំណុចទី ៦ នៃ សេចក្តីសំរេច ចោលជាអសារបង់ ។

ចំណុចក្រៅពីនេះ រក្សាទុកជាបានការដដែល ។

៥- រក្សាដីទំនាស់ស្ថិតនៅមុខផ្ទះលេខ ០៩ ( ជ ) ផ្លូវលេខ ២៧៣ សង្កាត់ទួលសង្កែ ខ័ណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ទុកសំរាប់ប្រើប្រាស់រួម ដល់អ្នកដែលរស់នៅក្នុងផ្ទះលេខ ០៩ ( ជ ) នេះ ទាំងអស់គ្នា ។

៦- បដិសេធលិខិតផ្ទេរសិទ្ធិកាន់កាប់ផ្ទះ និង ដី ចុះថ្ងៃទី ១៣-០២-២០០១ រវាងឈ្មោះ ព្រំ នឿន ប្រាក់ ឧត្តមមុនី និង ឈ្មោះ ផន បញ្ញា ចោលជាអសារបង់ ។

៧- កាត់យកប្រាក់ប្រដាប់ក្តី ជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀល គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹង ២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ ៥.០០០រៀល និងលើអាជ្ញាធរតុលាការ ៥.០០០រៀល សរុប ១៣.០០០រៀល ។

៨- សាលដីកានេះ ជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី ២៦-៨-២០០៣ ចំពោះមុខគូក្តី និង តតិយជន និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ០៥-៩-២០០៣ ចំពោះមុខគូក្តី និង តតិយជន បើកផ្លូវប្តឹងសាទុក្ខ តាមកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលេខ៣៦៥ ចុះថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០០៣ របស់លោក ខាន់ ង៉ែត និង ប្រពន្ធឈ្មោះ ប្រាក់ ពៅ មិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៣២ " ឈ " ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ លើ សាលដីកាទាំងមូល ។

បានឃើញ សារណាការពារ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៣ របស់ លោក ចាន់ សុខយាង ជាមេធាវី ការពារឱ្យ លោក ខាន់ ង៉ែត និង លោក ផន បញ្ញា ។

បានឃើញ សារណាតប ចុះថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០០៤ របស់លោក សំ វុទ្ធី

បានឃើញ សារណាតប ចុះថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០០៤ របស់អ្នកស្រី អោម ភីលន់

បានឃើញ ពាក្យសុំដកបណ្តឹងសាទុក្ខ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៤ របស់ លោក ខាន់ ង៉ែត និង ប្រពន្ធឈ្មោះ ប្រាក់ ឧត្តមផល្លី ហៅ ពៅ ។

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា :

- បណ្តឹងសាទុក្ខរបស់តតិយជន និង ដើមចោទ ធ្វើឡើងក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។

- សាលដីការដ្ឋប្បវេណីលេខ ១៣២ " ឈ " ចុះថ្ងៃទី ០៥-៩-២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវ ប្រសិនបើសំរេចអំពីការសាងសង់ផ្ទះ ប៉ុន្តែពុំមានភាពច្បាស់លាស់ ប្រសិនបើសំរេចអំពីសិទ្ធិលើដីទំនាស់ ។

សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់លោក ផន បញ្ញា បានឆ្លើយថា៖ខ្លួនមិនសុខចិត្តនឹងសាលដីកាសាលាឧទ្ធរណ៍ ដែលបានសំរេចពុំត្រឹមត្រូវ ដែលជាហេតុធ្វើឱ្យខូចប្រយោជន៍ ខ្លួនខ្លាំងណាស់ ព្រោះផ្ទះនេះ ខ្លួនបានទិញពីឈ្មោះ ព្រំ នឿន អស់លុយប្រាក់ម៉ឺនដុល្លា មុនទិញខ្លួនពុំបានស៊ើបសួរអ្វីទេ ប៉ុន្តែខ្លួនក៏ពុំបានដឹងថា ដីខាងមុខផ្ទះមានទំនាស់ដែរ ។ នៅពេលមុនខ្លួនចូលទៅទិញ គឺមានផ្ទះមួយហើយ ផ្ទះនេះជារបស់ ខាន់ ង៉ែត ដែលត្រូវជាកូនរបស់ឈ្មោះ ព្រំ នឿន ។ នៅពេលដែលអាជ្ញាធរមូលដ្ឋាន បានមកដាក់បញ្ជាឱ្យរុះរើផ្ទះណា ដែលនៅជាប់នឹងផ្លូវចេញ ហើយឈ្មោះខាន់ ង៉ែតក៏ត្រូវសាងសង់ផ្ទះថ្មីទៀត ហើយខ្លួនក៏ទៅប្តឹងជំទាស់ហាមឃាត់មិនឱ្យសាងសង់ផ្ទះថ្មីទៀត ។ ដីខាងមុខផ្ទះទំហំ ១២, ៧០ម × ៨, ៦០ម ជាដីមានផ្ទះទំនាស់ ហើយផ្ទះលេខ ៩ជ នៅខាងក្រោយផ្ទះទំនាស់នេះទេ ។

ក្រឡាបញ្ជីអានពាក្យសុំដកពាក្យបណ្តឹងសាទុក្ខ របស់លោក ខាន់ ង៉ែត និងប្រពន្ធឈ្មោះ ប្រាក់-ឧត្តមផល្លី ហៅ ពៅ ។

បានស្តាប់ចម្លើយរបស់ លោក សំ វុទ្ធី បានឆ្លើយថា ៖ តាំងពីឆ្នាំ ១៩៧៩ មក ផ្ទះទាំងមូលនេះត្រូវបាន ៣គ្រួសារជាអ្នករស់នៅទេ គ្មានឈ្មោះ ខាន់ ង៉ែត ទេ គេទើបតែមករស់នៅឆ្នាំ ១៩៨៤ នេះ ទេ ចំណែកឯឈ្មោះ ព្រំ នឿន មករស់នៅឆ្នាំ៨២ ហើយចេញទៅនៅខាងក្រៅឆ្នាំ៨៤ ដោយបានហៅឈ្មោះ ខាន់ ង៉ែត ជាកូនឱ្យមកនៅ ។ ចំណែកឯផ្ទះទំនាស់ ដែលខ្លួនបានប្តឹងហាមឃាត់ លោក ខាន់ ង៉ែត មិនឱ្យសាងសង់ ប៉ុន្តែ ខាន់ ង៉ែត នៅតែបន្តសាងសង់ដដែល គឺសង់នៅលើដីមុខផ្ទះខ្លួន គឺចំពីមុខបន្ទប់របស់ខ្លួនតែម្តង ។ ផ្ទះនៅលើដីទំនាស់នេះ គឺឈ្មោះ ខាន់ ង៉ែត និងប្រពន្ធឈ្មោះ ប្រាក់ ពៅ ជាអ្នកធ្វើ ដែលសង់ពីខែ ៤ ឆ្នាំ ២០០០ រហូតដល់ខែ ២ ឆ្នាំ២០០១ ទើបសង់ហើយ នៅលើដីទំនាស់មានផ្ទះ ១ ដែលលោក ផន បញ្ញា បានទទួលបញ្ចាំនោះ ។

សូមឱ្យតុលាការរុះរើផ្ទះខាងមុខ ដើម្បីងាយស្រួលក្នុងការរស់នៅផ្ទះនេះ ។

បានស្តាប់ចម្លើយរបស់ អ្នកស្រី អោម ភីលន់ ឆ្លើយថា ៖ ផ្ទះនេះ ខ្លួនចូលមករស់នៅតាំងពីឆ្នាំ៧៩ មក ហើយផ្ទះនេះ ជារបស់តាំងពីសង្គមចាស់មកម្លេះ ។ ក្រោយមកខ្លួនក៏បានហៅ ព្រំ នឿន មករស់នៅ ហើយខ្លួនបានប្រាប់ថា អ្នកឯងនៅតែតាមប្រលោះសសរនេះទេ ហើយកាន់កាប់តែប្រលោះសសរនេះទៅ ។ ក្រោយមកឈ្មោះ ព្រំ នឿន បានចេញទៅនៅខាងក្រៅជាមួយកូនរបស់គាត់ ហើយគាត់ក៏បានហៅកូនគាត់ ១ទៀត មករស់នៅឈ្មោះ ខាន់ ង៉ែត គេជាមនុស្សមានគំនិតលោភលន់ បានបិទច្រកចេញ-ចូល ទោះបីខ្លួនទៅប្តឹងអាជ្ញាធរ ឱ្យបើកផ្លូវយ៉ាងម៉េចក៏ដោយ ក៏គេមិនឱ្យចេញ-ចូល ដដែល ។ ទំនាស់នេះ គឺទាស់រឿងផ្ទះ ១ នៅពីមុខ ផ្ទះពូកខ្លួន ហើយលិចទឹកតែខែវស្សាទេ ឯខែប្រាំងពុំបានលិចទឹកទេ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ចាន់ សុខយាង ជាមេធាវី ការពារឱ្យ តតិយជន បញ្ជាក់ថា៖ រឿងនេះ គឺដោយមានការបង្វែរភាពដើម ១ ចំនួន ឱ្យខុសពីការពិតបាត់ទៅហើយ ។ មូលហេតុ

ដីទំនាស់នេះ មកពីលោក សំ វុទ្ធី មានដីនៅខាងក្រោយផ្ទះរបស់គាត់ទេ ដូចនេះហើយ ទើបមានគំនិតទាមទារយកដីខាងមុខផ្ទះនេះទៀត ។ ដំបូងឡើង គឺដីមុខផ្ទះ ខាងកើតមានយាយ សាត ជាអ្នកកាន់កាប់ ហើយបានលក់ឱ្យឪពុកក្មេក លោក សំ វុទ្ធី ឯដីខាងមុខផ្ទះ ខាងលិចនោះ គឺគ្រួសារ ព្រំ ឿននិង ខាន់ រ៉ែត ជាអ្នកកាន់កាប់ ។ មូលហេតុដែលកើតទំនាស់នេះ គឺកើតពេលគេពង្រីកផ្លូវ តាមពិតដីខាងមុខ ខាងលិច ជាការកាន់កាប់របស់ ព្រំ ឿន ។ តាមសាលក្រមរបស់តុលាការក្រុងភ្នំពេញ ក៏បានសំរេចឱ្យច្រកផ្លូវ ១ម ដើរចេញ-ចូល ហើយ ប៉ុន្តែផ្ទះដែលយាយសាតលក់ឱ្យឪពុកក្មេក សំ វុទ្ធី ហើយត្រូវបានរុះផ្ទះចេញអស់ហើយ ។ ខ្លួនបានចុះទៅដល់ គឺផ្ទះនេះ មានផ្ទះនៅខាងក្រោម ហើយក៏គ្មានទឹកលិចដែរ ។ ចម្លើយរបស់ លោកយាយ អោម ភីលន់ គឺមិនត្រឹមត្រូវទេ តាមពិតលោក សំ វុទ្ធី បានរុះផ្ទះចេញអស់ហើយ នៅសល់តែផ្ទះរបស់ ខាន រ៉ែត ដែលបានលក់ឱ្យ ផន បញ្ញា ទេ ពេលកូនក្តីខ្លួនទិញផ្ទះនេះគឺពុំមានទាក់ទិនជាមួយលោក សំ វុទ្ធី ទេ ព្រោះ ការហាមឃាត់នេះ គឺផ្ទះដែលទើបសាងសង់ ហើយផ្ទះដែលកូនក្តីខ្លួនទិញនេះ មុនទំនាស់កើតឡើង ។

ខ្លួនយល់ថា សាលដីការបស់សាលាឧទ្ធរណ៍នេះ បានសំរេចមិនត្រឹមត្រូវទេ ។

បានស្តាប់ចម្លើយរបស់លោក សំ វុទ្ធី ឆ្លើយបន្ថែមទៀតថា : ខ្លួនសុំជំទាស់ថា នៅខាងក្រោមផ្ទះពិតជាលិចទឹកត្រឹមជង្គង់មែន ចំណែកផ្ទះកំពុងសាងសង់ថ្មីនោះ គឺពិតជាផ្ទះដែលខ្លួនកំពុងប្តឹងហាមឃាត់ការសាងសង់នេះ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ចាន់ សុខយាង ជាមេធាវីការពារឱ្យតតិយជនបញ្ជាក់បន្ថែមទៀតថា : គាត់បានអះអាងថា សាងសង់ផ្ទះតាំងពីឆ្នាំ ២០០០រួចមកហើយ ។ ហើយការតផ្ទះនេះ ពុំមែនប៉ះពាល់នឹងផ្ទះ លោក សំ វុទ្ធី ទេ ប៉ុន្តែលោកយាយ អោម ភីលន់ គ្មានផ្ទះរស់នៅទេ សព្វថ្ងៃគេរុះផ្ទះគាត់អស់ហើយ ហើយគេបានចាក់ដីលុបពេញអស់ទៅហើយ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ពាក្យបណ្តឹងសុំជកបណ្តឹងសាទុក្ខរបស់ឈ្មោះ ខាន់ រ៉ែត និង ប្រាក់-ឧត្តមផល្លី ចម្លើយរបស់លោក ផន បញ្ញា ចម្លើយរបស់លោក សំ វុទ្ធី ចម្លើយរបស់អ្នកស្រី អោម ភីលន់ និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីតតិយជន
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

# តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៦២ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០៣ របស់លោក ផន-បញ្ញា និង បណ្តឹងសាទុក្ខលេខ ៣៦៥ ចុះថ្ងៃទី ១៧-៩-២០០៣ របស់ឈ្មោះ ខាន់ ម៉ែត និង ប្រាក់ ពៅ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ឈ្មោះ ខាន់ ម៉ែត និង ប្រាក់ ពៅ បានប្តឹងសុំដកបណ្តឹងសាទុក្ខ តាមពាក្យបណ្តឹង ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៤ តុលាការកំពូល គប្បីអនុញ្ញាតតាមសុំ ។

- យល់ឃើញថា តាមលិខិតលេខ ២១៣១ របន.អន ចុះថ្ងៃទី ០៦-០៧-២០០១ របស់ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដីរាជធានីភ្នំពេញ បញ្ជាក់ថា :

  - ការសាងសង់ធ្វើឡើងដោយឈ្មោះ ព្រុំ នឿន គ្មានច្បាប់អនុញ្ញាត ការសាងសង់ធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយរបស់អាជ្ញាធរ និង ប៉ះពាល់ដល់សិទ្ធិរបស់អ្នកជនៃ ។
  - បើទុកសំណង់នេះ បណ្តាលឱ្យខូចខាតប្រយោជន៍របស់គ្រួសារ ដែលបានកាន់កាប់ស្នាក់នៅក្នុងក្បាលដីនេះ ព្រោះគ្រួសារទាំងនោះ មានសិទ្ធិប្រើប្រាស់សំរាប់សេវារួមលើដីទំនាស់នោះ ។

- យល់ឃើញថា ការសាងសង់ផ្ទះដោយ ឈ្មោះ ព្រុំ នឿន ខាន់ ម៉ែត និង ប្រពន្ធ ប្រាក់ ពៅ គឺជាការសាងសង់ដោយបំពានទៅនឹងការហាមឃាត់របស់អាជ្ញាធរមានសមត្ថកិច្ច ដូចមានក្នុងលិខិតលេខ ០០៧របកចុះថ្ងៃទី ០២-០៦-២០០០ និង លិខិតលេខ ១៦៤ រប ចុះថ្ងៃទី ២៥-០៧-២០០០ របស់ការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និង ភូមិបាលខ័ណ្ឌឫស្សីកែវ ដីកាសំរេចលេខ ២៦ " ក " ចុះថ្ងៃទី ២៤-០៤-០១ របស់តុលាការក្រុងភ្នំពេញ និង លិខិតផ្សេងៗ ទៀត របស់អាជ្ញាធរមានសមត្ថកិច្ច ។

- យល់ឃើញថា ការដែលលោក ផន បញ្ញា អះអាងថា ខ្លួនមានសិទ្ធិលើដី និង ផ្ទះទំនាស់ ដោយសំអាងទៅលើលិខិតផ្ទេរកម្មសិទ្ធិកាន់កាប់ដី និង ផ្ទះ ចុះថ្ងៃទី ១៣-០២-២០០១ ពីឈ្មោះ ព្រុំ នឿន គឺជាការអះអាងពុំត្រឹមត្រូវឡើយ ពីព្រោះថា ការកំណត់សិទ្ធិតាមផ្លូវច្បាប់អំពីបុគ្គលដែលត្រូវមានសិទ្ធិលើដីនោះ ពុំទាន់មាននៅឡើយ រីឯផ្ទះដែលបានសង់វិញ គឺជាការសាងសង់ដោយបំពានច្បាប់ ដែលជាអំពើអនីត្យានុកូល ប្រព្រឹត្តដោយឈ្មោះ ព្រុំ នឿន ។ ដូច្នេះ កិរិយារបស់ឈ្មោះ ព្រុំ នឿន ទាំងនេះនាំឱ្យលិខិតផ្ទេរកម្មសិទ្ធិកាន់កាប់ដី និង ផ្ទះ ចុះថ្ងៃទី ១៣-០២-២០០១ ពីឈ្មោះ ព្រុំ នឿន ទៅឈ្មោះ ផន បញ្ញា ពុំមានតម្លៃតាមផ្លូវច្បាប់បានឡើយ ។

- យល់ឃើញថា ការលើកឡើងរបស់មេធាវីតតីយជន នាសវនាការនេះ ថា ផ្ទះរបស់លោកយាយ

ព្រំ នឿន ជាសំណង់ចាស់ មុនទំនាស់នោះ គឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា តាមកំណត់ហេតុ ចុះថ្ងៃទី ១៨-៨-២០០០ អាជ្ញាធរមូលដ្ឋាន បានហាមឃាត់ការសាងសង់ ហើយលោកយាយ ព្រំ នឿន ក៏បានឯកភាពផ្អាកការសាងសង់នេះដែរ ។

- យល់ឃើញថា ឈ្មោះ ខាន់ ម៉ែត និង ប្រាក់ ឧត្តមផល្លី បានទទួលដីកាកោះហើយ ប៉ុន្តែពុំបានចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូល ជំនុំជំរះរឿងនេះ កំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១៣២ " ឈ " ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី ចំពោះមុខដើមចោទ និង តតិយជន

## កំបាំងមុខឈ្មោះខាន់ ម៉ែត និងឈ្មោះ ប្រាក់ ឧត្តមផល្លី

## ប៉ុន្តែចាត់ទុកជាចំពោះមុខ

១- ទទួលបណ្តឹងសាទុក្ខលេខ ៣៦២ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ របស់ឈ្មោះ ផន បញ្ញា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- ទទួលពាក្យបណ្តឹងសុំដកបណ្តឹងសាទុក្ខ ចុះថ្ងៃទី ១២-០១-២០០៤ របស់លោក ខាន់ ម៉ែត និង អ្នកស្រី ប្រាក់ ឧត្តមផល្លី ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣- អនុញ្ញាតឱ្យឈ្មោះ ខាន់ ម៉ែត និង ប្រាក់ ពៅ ដកបណ្តឹងសាទុក្ខតាមសុំ ។

៤- តម្កល់សាលដីការដ្ឋប្បវេណីលេខ ១៣២" ឈ " ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទំាងមូល ។

៥- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៥.០០០រៀល ដែលចុងចម្លើយបានបង់គឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វីង ចំនួន ៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

- ចំណាយលើការប្រគល់ដីកាកោះ ចំនួន ១៥០០០ រៀល សរុប ១៥០០០រៀល

- បង្គាប់ឱ្យឈ្មោះ ផន បញ្ញា សងប្រាក់ចំនួន ១៥.០០០រៀល ទៅដើមចោទវិញ ។

បង្គាប់ឱ្យឈ្មោះ ផន បញ្ញា បង់ពន្ធសមាមាត្រ១% លើតម្លៃដី និងផ្ទះទំនាស់ដែលលោកផន បញ្ញា

បានទិញពីលោកយាយ ព្រុំ នឿន ។

៦- សាលដីកានេះ ជំនុំជំរះជាសាធារណៈនៅថ្ងៃទី ០៩ខែកញ្ញា ឆ្នាំ២០០៤ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៤ ។